

# សន្លឹកព័ត៌មាន

## សញ្ញាជីវសុវត្ថិភាពនៅច្រកទ្វារកសិដ្ឋាន

សញ្ញាជីវសុវត្ថិភាពនៅលើច្រកទ្វារកសិដ្ឋាន ផ្ញើសារខ្លាំងមួយទៅកាន់អ្នកចូលទស្សនា ថាអ្នកដឹងពីជីវសុវត្ថិភាព ហើយរំពឹងថាមនុស្សទាំងឡាយគោរពតាមនីតិវិធីជីវសុវត្ថិភាពដែលមាន។ សញ្ញាក្លាយជាការសំខាន់ពិសេស នៅពេលតំបន់ដាំដុះស្ថិតនៅក្នុងទីតាំងនៅក្នុងតំបន់ចន្លោះទីក្រុង ដែលចរាចរណ៍អាចចូលមកក្នុងកសិដ្ឋានជារឿយៗ។

*តើមានព័ត៌មានអ្វីខ្លះដែលត្រូវរួមបញ្ចូលនៅលើសញ្ញាជីវសុវត្ថិភាពនៅច្រកទ្វារកសិដ្ឋាន?*

សញ្ញាជីវសុវត្ថិភាពនៅច្រកទ្វារកសិដ្ឋានត្រូវ ណែនាំអ្នកចូលទស្សនាឱ្យទាក់ទងម្ចាស់ ឬ អ្នកគ្រប់គ្រងកសិដ្ឋាន ដើម្បីចុះឈ្មោះជាផ្លូវការ វត្តមានរបស់ពួកគេ នៅមុនពេលចូលទៅក្នុងអចលនទ្រព្យ។ សញ្ញាត្រូវរួមបញ្ចូលនូវព័ត៌មានទំនាក់ទំនងលម្អិត ដែលពាក់ព័ន្ធ ក៏ដូចជាសារបញ្ជាក់ ថាការចូលទៅកាន់អចលនទ្រព្យតម្រូវឱ្យ អ្នកចូលទស្សនាគោរពតាមវិធានការជីវសុវត្ថិភាពនានាដែលមាននៅលើកសិដ្ឋាន។

សញ្ញាជីវសុវត្ថិភាពត្រូវរចនាឡើងដោយមានអក្សរជិតច្បាស់ មានពណ៌ផ្ទុយគ្នាសម្រាប់ធន់នឹងផលប៉ះពាល់ខ្លាំបំផុត។ ពណ៌ក្រហម ពណ៌ខ្មៅ និងពណ៌សគឺជាការផ្សំពណ៌មួយ ដែលគេបានឃើញជាទូទៅនៅលើសញ្ញាជីវសុវត្ថិភាព។ បន្ទះ Corflute ឬលោហៈជាសម្ភារពេញនិយមសម្រាប់ការផលិតសញ្ញាច្រកទ្វារកសិដ្ឋាន។

### *ដើម្បីឱ្យមានប្រសិទ្ធភាព សញ្ញាត្រូវ៖*

- **ដាក់នៅកន្លែងដែលអ្នកចូលទស្សនាមិនអាចប៉ះពាល់បាន តែអាចកត់សម្គាល់បាន**
- **ត្រូវច្បាស់ អាចមើលឃើញ និងមានការក្សាទុកបានល្អ**
- **ត្រូវដាក់នៅទីតាំងត្រង់ច្រកចូលសំខាន់ៗទៅកាន់អចលនទ្រព្យ**
- **មានសារសាមញ្ញៗ**
- **ត្រូវបានពង្រឹងជាមួយនឹងវិធានការជីវសុវត្ថិភាពនានាផ្សេងទៀតដែលនៅលើកសិដ្ឋាន**

*ខ្ញើសញ្ញាជីវសុវត្ថិភាពនៅច្រកទ្វារកសិដ្ឋានគ្រប់គ្រាន់សម្រាប់កាត់បន្ថយហានិភ័យពីសត្វល្អិតចង្រៃ រុក្ខជាតិតូចៗឥតប្រយោជន៍ និងជំងឺឬទេ?*

សញ្ញាច្រកទ្វារកសិដ្ឋានមិនមែនជាវិធានការជីវសុវត្ថិភាពតែឯកឯងទេ។ សារជីវសុវត្ថិភាពជាសញ្ញាត្រូវការពង្រឹងតាមរយៈវិធានការជីវសុវត្ថិភាពបន្ថែមទៀតនៅលើកសិដ្ឋាន ដើម្បីកាត់បន្ថយហានិភ័យដែលបង្កឡើងដោយជំងឺ សត្វល្អិតចង្រៃ និងរុក្ខជាតិតូចៗឥតប្រយោជន៍នានា។

### សញ្ញាបន្ថែមនៅក្នុងអចលនទ្រព្យក៏សំខាន់ផងដែរ។

ហេតុផលសំខាន់មួយសម្រាប់ដំឡើងសញ្ញាជីវសុវត្ថិភាពកសិដ្ឋាន គឺដើម្បីធ្វើឱ្យប្រាកដថាអ្នកចូលទស្សនាកសិដ្ឋានមិនចូលតំបន់ដាំដុះដោយចៃដន្យ។ សញ្ញាបន្ថែមអាចត្រូវបានប្រើប្រាស់ដើម្បី៖

- ផ្តល់នូវទិសដៅច្បាស់ទៅកាន់កន្លែងចតរថយន្តរបស់អ្នកចូលទស្សនា
- ណែនាំអ្នកចូលទស្សនាទៅការិយល័យអចលនទ្រព្យដែលពួកគេអាចចុះហត្ថលេខាក្នុងបញ្ជីអ្នកចូលទស្សនា និងធ្វើការណែនាំដំបូងអំពីកសិដ្ឋាន
- បង្ហាញថាពេលណាដែលអ្នកនឹងចូលតំបន់ដែលដាក់កំហិត
- ណែនាំអ្នកចូលទស្សនាឱ្យលាងជើង
- បង្ហាញទីតាំងនៃយានជំនិះ ឬម៉ាស៊ីន កន្លែងសម្អាត




**ទាក់ទង AUSVEG តាមលេខ 03 9882 0277 ដើម្បីទទួលបានទម្រង់គំរូសញ្ញាជីវសុវត្ថិភាពអេឡិចត្រូនិក ឬទាញយកវាពីគេហទំព័រ AUSVEG នៅឯ ausveg.com.au/biosecurity**

សត្វល្អិតចង្រៃមិនប្រក្រតីនៅលើរុក្ខជាតិត្រូវរាយការណ៍ជាបន្ទាន់ទៅទីភ្នាក់ងារកសិកម្មដែលពាក់ព័ន្ធនៅតាមរដ្ឋ ឬដែនដីតាមខ្សែទូរសព្ទស្តីពីសត្វល្អិតចង្រៃចម្លែកលើរុក្ខជាតិតាមលេខ (1800 084 881)។
សម្រាប់ព័ត៌មានបន្ថែម សូមមើលគេហទំព័រជីវសុវត្ថិភាពនៅឯ farmbiosecurity.com.au ឬទាក់ទង AUSVEG តាមលេខ (03) 9882 0277។

